វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

# ឯកសារស្រាវជ្រាវសង្ខេប

ភូមិភាគទី៥ ព្រឹទ្ធសភា

# ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ

ខែ កុម្ភៈ ឆ្នាំ ២០២០


រៀបចំដោយៈ លោកស្រី គុប ដាវី
លោកស្រី កឹម កែវធីតា

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការ ផ្តល់នូវឯកសារស្រាវជ្រាវតែបតាមសំណើរបស់សមាជិក សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារនេះផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ ។

ខ្លឹមសារនៃឯកសារនេះមានកំណត់កាលបរិច្ឆេទច្បាស់លាស់ ដើម្បីផ្តល់ជាឯកសារជំនួយស្មារតីតបតាមម្ចាស់សំណើ ។ ឯកសារនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬគោលនយោបាយណាមួយឡើយ ដោយផ្តោតតែលើព័ត៌មានពីឯកសារដែលមានស្រាប់ និងមិនបានសិក្សាឲ្យ គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅនឹងបញ្ហាលម្អិតនៃការស្រាវជ្រាវសង្ខេបនោះទេ ពោលគឺដើម្បីឆ្លើយតបទៅនឹងសំណើដែលទទួលបានតែប៉ុណ្ណោះ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំចងក្រងឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថានសភាកម្ពុជា។

©រក្សាសិទ្ធិ ឆ្នាំ២០២០ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# អក្សរកាត់

| | |
|---|---|
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីស្ត្រី និងកុមារឃុំ សង្កាត់ |
| CCWC FP | ជនបង្គោលគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីស្ត្រី និងកុមារឃុំ សង្កាត់ |
| CIP | កម្មវិធីវិនិយោគឃុំ សង្កាត់ |
| CDP | ផែនការអភិវឌ្ឍឃុំ សង្កាត់ |
| CIF | មូលនិធិវិនិយោគឃុំ សង្កាត់ |
| ឃ.ស | ឃុំ សង្កាត់ |
| CSFMS | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ |
| ID | អត្តសញ្ញាប័ណ្ណ |
| MCHN | សុខភាពមាតា និងទារក និងអាហាររូបត្ថម្ភ |
| MoI | ក្រសួងមហាផ្ទៃ |
| MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoSVY | ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា |
| គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SNAs | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SSP | គោលនយោបាយសុវត្ថិភាពឃុំ សង្កាត់ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| គ.ក.ស.ក | គណៈកម្មាធិការពិគ្រោះយោបល់ ស្ត្រី និងកុមារ |

# មាតិកា


តារាង និងក្រាហ្វិក.......................................................................................i

១. សេចក្តីផ្តើម ..........................................................................................1

២. ទិដ្ឋភាពទូទៅខេត្តតាកែវ ........................................................................1

៣. មុខងារក្រុមប្រឹក្សាឃុំ សង្កាត់ ................................................................5

៣.១. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីស្ត្រី និងកុមារឃុំ សង្កាត់(គ.ក.ន.ក)

៤. ផែនការថវិកាក្រុមប្រឹក្សាឃុំ សង្កាត់ ......................................................7

៤.១. ថវិកា ឃុំ សង្កាត់ ...................................................................................8

៤.២. ដំណើរការការធ្វើផែនការថវិកាឃុំ សង្កាត់ .............................................9

៤.៣. បញ្ហាប្រឈមដែលក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក បានប្រឈមក្នុងការអនុវត្តតួនាទី 10

៤.៤. ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងផែនការថវិកា............................................. 11

៥. ជម្រើសគោលនយោបាយ.........................................................................12

ឯកសារយោង...........................................................................................15

# តារាង និងក្រាហ្វិក


តារាង 1៖ មុខរបរចម្បងបុរស និងស្ត្រីអាយុចាប់ពី ១៨ ឆ្នាំឡើងលើ ឆ្នាំ ២០១៨............................2
ក្រាហ្វិក 1៖ ការផ្លាស់ប្តូរចំនួនករណីរដ្ឋប្បវេណីនិ ងព្រហ្មទណ្ឌតាមស្រុកនៅខេត្តតាកែវ ..................3
ក្រាហ្វិក 2៖ករណីសន្តិសុខ ឆ្នាំ ២០១៨..........................................................................................4
ក្រាហ្វិក 3៖ករណីព្រួយបារម្ភនៅក្នុងខេត្តតាកែវ  ២០១៨........................................................4
ក្រាហ្វិក 4៖រចនាសម្ពន្ធ័ក្រុមប្រឹក្សាឃុំ សង្កាត់..................................................................................5
ក្រាហ្វិក 5៖ថវិកាខេត្ត និង ឃុំ សង្កាត់ (លានរៀល) ................................................................8
ក្រាហ្វិក 6៖ការចំណាយថវិកាសម្រាប់មនុស្សម្នាក់តាមបណ្តាខេត្តនៅឆ្នាំ ២០២០..........................9

# ១. សេចក្តីផ្តើម

ឯកសារស្រាវជ្រាវសង្ខេបនេះផ្តល់ព័ត៌មានជូនភូមិភាគ៥ព្រឹទ្ធសភា សម្រាប់ចូលរួមវេទិកាសាធារណៈស្តីពី «សមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ» នៅក្នុងខេត្តតាកែវ នាចុងខែ មីនា ឆ្នាំ ២០២០ ខាងមុខនេះ។

ឯកសារនេះបង្ហាញពីទិដ្ឋភាពទូទៅនៃបញ្ហាប្រឈមដែលក្រុមប្រឹក្សាឃុំ សង្កាត់(ឃ.ស) និង គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីស្ត្រី និងកុមារឃុំ សង្កាត់(គ.ក.ន.ក) ជួបប្រទះ ក្នុងការទទួលបានធនធានសម្រាប់បំពេញតួនាទីរបស់ខ្លួននិងធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈជូនប្រជាជន។ ភស្តុតាងទាំងនេះបានមកពីការសិក្សាទិន្នន័យដែលមានស្រាប់នៅបណ្ណាល័យគ.ជ.អ.ប និងតាមប្រព័ន្ធអ៊ិនធែណែតតែប៉ុណ្ណោះឆ្លើយសំនួរ៥ខាងក្រោមដូចខាងក្រោមៈ

១. តើក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទីអ្វីខ្លះ? តើគណៈកម្មការពិគ្រោះយោបល់កិច្ចការងារស្ត្រី និងកុមារ មានតួនាទីអ្វីខ្លះ?
២. តើក្រុមប្រឹក្សាឃុំ សង្កាត់មានបញ្ហាអ្វីខ្លះក្នុងការអនុវត្តតួនាទីរបស់ពួកគាត់?
៣. តើឃុំ/សង្កាត់ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះក្នុងការរៀបចំគម្រោងថវិកា?
៤. តើក្របខ័ណ្ឌគតិយុត្ត និងការអនុវត្តគម្រោងថវិកាឃុំ/សង្កាត់បច្ចុប្បន្នមានអ្វីខ្លះ?
៥. តើមានជម្រើសគោលនយោបាយអ្វីខ្លះដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ?

# ២. ទិដ្ឋភាពទូទៅខេត្តតាកែវ

ខេត្តតាកែវមានផ្ទៃដីសរុបចំនួន ៣.៧៥៤.៤៣ គីឡូម៉ែត្រការ៉េ គឺជាខេត្តទី៧ ដែលមានផ្ទៃដីតូចជាងគេក្នុងចំណោម ២៥ ខេត្តក្រុង[7]។ ខេត្តនេះស្ថិតនៅប៉ែកខាងត្បូងឈាងខាងលិចនៃប្រទេសកម្ពុជា និងមានព្រំប្រទល់ខាងលិចជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តកំពត ហើយខាងត្បូងទល់នឹងប្រទេសវៀតណាម។ ខេត្តនេះមានសង្កាត់ចំនួន បី ស្រុក ១០ ឃុំ ៩៧ និងភូមិ ១.១១៩[3, 8, 9]។ នៅក្នុងឆ្នាំ ២០១៩ តាកែវមានប្រជាជនសរុបចំនួន ៨៩៩.៤៨៥ នាក់ (ស្ត្រីមានចំនួន ៤៦៦.៨៣៦ នាក់) និង ១៩៩.៣៦២ ចំនួនគ្រួសារ[7]។ តាកែវជាខេត្តទីបីដែលមានដង់ស៊ីតេប្រជាជនខ្ពស់ (ប្រជាជន ២៥២ នាក់ក្នុង ១គីឡូម៉ែត្រការ៉េ) បន្ទាប់ពីខេត្តកណ្តាល (៣៧៦ ក្នុងគីឡូម៉ែត្រការ៉េ) និង ភ្នំពេញ (៣១៣៦ គីឡូម៉ែត្រការ៉េ)។

## ជីវភាពរស់នៅ

បុរសស្ត្រីភាគច្រើនមានមុខរបរចម្បង ក្នុងវិស័យកសិកម្ម បន្ទាប់មកសេវាកម្ម។ ក្នុងចំណោមស្រុកទាំង ១០ ស្រុកព្រៃ កប្បាស មានភាគរយបុរស (០,៧ ភាគរយ) និងស្ត្រី (៥,៩ ភាគរយ) ច្រើនជាងគេប្រកបការងារក្នុងវិស័យសិប្បកម្ម បើប្រៀបធៀបនឹងស្រុកដទៃទៀត សមាមាត្របុរស (តារាងទី ១) ។

*ផែនទី ១៖ ខេត្តតាកែវ*




*Source: Prevalence and risk factors of Strongyloides stercoral is in Takeo Province, 2014 [5]*

ទិន្នន័យឃុំ ឆ្នាំ ២០១៨ បានបង្ហាញថាខេត្តជីស្រែមានទំហុះ ៥២ ភាគរយនៃផ្ទៃដីដាំដុះសរុបប្រមាណ ៥៧០.២៧៦ ហិតា រីឯដីចំការមានប្រហែល ១៥ ភាគរយ និងនៅសល់ ៣៣ ភាគរយ សម្រាប់គោលបំណងផ្សេងទៀត។ នៅឆ្នាំ ២០១៨ មានតែ ៦៨ ភាគរយនៃផ្ទៃដីសរុប ២៩៦.៤៣៥ ហិតាដែលបានដាំដុះ និង ប្រមូលផល សរុបបានទាំងអស់ចំនួន ៦៧៤.៦៩៤ តោន។ ផលសរុបនេះបានរួមចំណែក៨ ភាគរយនៃផលស្រូវសរុបទូទាំងប្រទេសចំនួន ៨.៤៤៨. ២១១ តោន [3] ដែលបាននាំឲ្យខេត្តតាកែវក្លាយជាខេត្តធំទីបីខាងផលិតស្រូវ បន្ទាប់ពីខេត្តព្រៃវែង ១.៩៧៤.១០៦ តោន និងបាត់ដំបង ៨៧៦.១៧០ តោន។ ខេត្តតា-កែវទទួលបានទិន្នផលស្រូវរដូវប្រាំងជាមធ្យមប្រហែល ៤,៣ តោនក្នុងមួយហិតា ខ្ពស់ជាងគេ និងសម្រាប់ស្រូវវស្សា ប្រហែល ២,៧ តោនក្នុងមួយហិកតា ជាប់ចំណាត់ថ្នាក់ទីបី បន្ទាប់ពីខេត្តកែប (៣ តោនក្នុងមួយហិតា) កំពង់ចាម (២,៩ តោនក្នុងមួយហិតា) និងកណ្ដាល (២,៨ តោនក្នុងមួយហិតា) [3]។

*តារាង 1៖ មុខរបរចម្បងបុរស និងស្ត្រីអាយុចាប់ពី ១៨ ឆ្នាំឡើងលើ ឆ្នាំ ២០១៨*

| | សរុបចំនួនបុរស និងស្ត្រី | បុរស | ស្ត្រី | កសិកម្ម | | សេវាកម្ម | | សិប្បកម្ម | |
|---|---|---|---|---|---|---|---|---|---|
| | | | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| **តាកែវ** | ៤៧៤.៥១៩ | ២៤៤.០៣០ | ២៣០.៤៨៩ | ៧២ % | ៦៦ % | ២៨ % | ៣៣ % | ០,៤ % | ១,១ % |
| កោះអណ្ដែត | ២៧.១៩៣ | ១៤.៨១៧ | ១២.៣៧៦ | ៧៧ % | ៧៦ % | ២៣ % | ២៣ % | ០,១ % | ០,៤ % |
| គីរីវង់ | ៤៩.៨៥៧ | ២៧.៧២៥ | ២២.១៣២ | ៧៤ % | ៧៧ % | ២៦ % | ២៣ % | ០,២ % | ០,២ % |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ដូនកែវ | ១៧.៨២៥ | ៩.៩១៦ | ៧.៩០៩ | ៥៣% | ៥៥% | ៤៦% | ៤៥% | ០,៥% | ០,២% |
| ត្រាំកក់ | ៩៦.៦១៣ | ៤៨.៣០១ | ៤៨.៣១២ | ៧៣% | ៦៧% | ២៧% | ៣៣% | ០,៤% | ០,៥% |
| ទ្រាំង | ៥៣.៩០៨ | ២៧.៩៩៣ | ២៥.៩១៥ | ៦៩% | ៧០% | ៣១% | ៣០% | ០,៣% | ០,៥% |
| បាទី | ៨២.៧៥៩ | ៣៨.២៦០ | ៤៤.៤៩៩ | ៦៧% | ៥១% | ៣៣% | ៤៨% | ០,៣% | ០,៩% |
| បូរីជលសារ | ១២.៥០១ | ៧.៣១០ | ៥.១៩១ | ៨៧% | ៨៧% | ១៣% | ១៣% | ០% | ០% |
| ព្រៃកប្បាស | ៤៦.២៦៣ | ២៤.៤៧៦ | ២១.៧៨៧ | ៧៥% | ៦៨% | ២៤% | ២៦% | ០,៧% | ៥,៩% |
| សំរោង | ៦៩.២១៧ | ៣៤.១៨៣ | ៣៥.០៣៤ | ៧៥% | ៦៥% | ២៥% | ៣៤% | ០,៣% | ០,៨% |
| អង្គរបូរី | ១៨.៣៨៣ | ១១.០៤៩ | ៧.៣៣៤ | ៧៤% | ៧៦% | ២៦% | ២៤% | ០,២% | ០,២% |

*ប្រភព៖ ទិន្នន័យឃុំ ឆ្នាំ ២០១៨[3]*

## សណ្តាប់ធ្នាប់ និងសន្តិសុខសង្គម

ការធានាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមឲ្យប្រជាជន គឺជាតម្រូវការចាំបាច់ សម្រាប់ធានាសន្តិភាព សម្រាប់ការអភិវឌ្ឍន៍ក្នុងតំបន់ និងសុខុមាលភាពប្រជាជនកម្ពុជា។ ក្តីកង្វល់ពីសន្តិសុខ និងសណ្តាប់ធ្នាប់ប្រាំពីរស្រុកក្នុងខេត្តតាកែវហាក់មានការធ្លាក់ចុះ។ ប៉ុន្តែផ្ទុយទៅវិញបើយោងលើទិន្នន័យឃុំ នៅ

*ក្រាហ្វិក 1៖ ការផ្លាស់ប្តូរចំនួនករណីរដ្ឋប្បវេណីនិ ងព្រហ្មទណ្ឌតាមស្រុកនៅខេត្តតាកែវ*




*ប្រភព៖ ទិន្នន័យឃុំ ២០១០ និង២០១៨ [3, 6]*

ចន្លោះឆ្នាំ ២០១០ និង ២០១៨ ស្រុកបូរីជលសារ បាទី និង ត្រាំកក់ ករណីបទល្មើសមួយចំនួន ហាក់

មានការកើនឡើងពី ៦ ទៅ ៧% (ក្រាហ្វិកទី ១)។ ការព្រួយបារម្ភបែបនេះអាចមកពីការកើនឡើងនូវសមត្ថភាពកត់កំណត់ហេតុរបស់ក្រុមប្រឹក្សា ឃ.ស. ឬ អាចនិយាយថាករណីបានកើនឡើងនៅតាមបណ្តាស្រុកទាំងនោះពិតមែន។ បញ្ហាទាំងនេះអាចជាប្រធានបទមួយសម្រាប់ការពិភាក្សាបន្ថែមទាក់ទងនឹងបញ្ហាយេនឌ័រផងដែរក្នុងកំឡុងពេលបំពេញបេសកកម្ម។

ទាក់ទងនឹងបញ្ហាសន្តិសុខ ក្រុមប្រឹក្សាឃ.ស. ប្រហែលជាកំពុងប្រឈមនឹងបញ្ហានានាជាច្រើនក្នុងការធានា សណ្តាប់ធ្នាប់ និងសន្តិសុខសង្គមក្នុងតំបន់របស់ខ្លួន ដោយមានករណីជាច្រើនទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀន អំពើហឹង្សាក្នុងគ្រួសារ ករណីព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណី កើតឡើងច្រើនជាងគេនៅក្នុងស្រុកបាទី សំរោង និងព្រៃកប្បាស។ បញ្ហាញៀនថ្នាំ និងអំពើហឹង្សាក្នុងគ្រួសារហាក់ដូចជាបញ្ហាប្រឈមខ្លាំងជាងគេ ដែលក្រុមប្រឹក្សាឃ.ស. ត្រូវដោះស្រាយនាឆ្នាំកន្លងមក (ក្រាហ្វិក២)។

*ក្រាហ្វិក២៖ ករណីសន្តិសុខ ឆ្នាំ ២០១៨*




*ប្រភព៖ ទិន្នន័យឃុំ ២០១៨[3]*

*ក្រាហ្វិក៣៖ ករណីព្រួយបារម្ភនៅក្នុងខេត្តតាកែវ ២០១៨*




*ប្រភព៖ ទិន្នន័យឃុំ ២០១៨*

ខេត្តតាកែវក៏បានជួបប្រទះករណី វិវាទដីធ្លី និងករណីព្រហ្មទណ្ឌ ចំនួន ១៧ ភាគរយ និង ៩ ភាគរយនៃ ៥.៣៦៩ ករណី។ ករណីវិវាទដីធ្លីបានកើតឡើងនៅស្រុកត្រាំកក់ សំរោង ព្រៃកប្បាស គីរីវង់ និងបាទីមានចំនួនច្រើនជាងស្រុកដ៏ទៃទៀត (ក្រាហ្វិកទី ៣)។ លំនាំនៃវិវាទបែបនេះអាចប្រហែលជាទាក់ទងនឹងការអភិវឌ្ឍទីផ្សារដីធ្លី និងដំណើរការនៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុងតំបន់ទាំងនោះ។ ជាធម្មតា ករណីព្រហ្មទណ្ឌមានចំនួន ៩ ភាគរយនៃករណីសរុបទាំងអស់ ប៉ុន្តែសម្រាប់ស្រុកត្រាំកក់ និងអង្គរបុរីវាហាក់ជាក្តីបារម្ភជាងស្រុកដ៏ទៃទៀតដោយសារមានអត្រាប្រេវ៉ាឡង់ខ្ពស់នៃករណីព្រហ្មទណ្ឌ។ ដោយ-

សារមានករណីច្រើនដូចដែលបានបញ្ជាក់នៅក្នុងក្រាហ្វិកទី ២ ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពី ឃ.ស. ដើម្បីគ្រប់គ្រងកង្វល់ទាំងនោះ។

### បម្រែបម្រួលអាកាសធាតុ

ដូចនឹងខេត្តដ៏ទៃទៀតដែរនៅប្រទេសកម្ពុជា ប្រជាជនដែលរស់នៅក្នុងខេត្តតាកែវ ទទួលរងនូវឥទ្ធិពលអាក្រក់ពីបម្រែបម្រួលអាកាសធាតុកន្លងមកនេះ ។ ឧទាហរណ៍នៅឆ្នាំ ២០១៨ គ្រោះរាំងស្ងួតបានប៉ះពាល់ដល់ប្រជាជន ចំនួន ២០៣២ គ្រួសារ នៅស្រុកត្រាំកក់ ១៤៤៦ គ្រួសារ នៅកោះអណ្តែត និង ១២៧៥ គ្រួសារនៅស្រុកទ្រាំង[3]។ ហើយប្រជាជនជាច្រើននៅស្រុកគិរីវង់ ស្រុកសំរោង និងស្រុកបាទីបានរាយការណ៍ពីការរងគ្រោះដោយទឹកជំនន់នៅឆ្នាំ ២០១៨ផងដែរ [3]។

## ៣. មុខងារក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃ.ស. មានអាណត្តិផ្លូវការ ៥ ឆ្នាំ តាមរយៈការបោះឆ្នោតចាប់តាំងពីឆ្នាំ ២០០២ កំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ ២០០១ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាមានតួនាទីធំពីរ៖ (១)បម្រើការងារក្នុងមូលដ្ឋានដើម្បីផលប្រយោជន៍ ឃ.ស. និងប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ និង (២) ធ្វើជាទីភ្នាក់ងាររដ្ឋាភិបាលក្រោមការចាត់តាំង និងប្រតិភូកម្មអំណាចរបស់រដ្ឋាភិបាលកណ្តាល [4, p. 8]។

ក្រុមប្រឹក្សាឃុំ សង្កាត់ នីមួយៗមានសមាជិកក្រុមប្រឹក្សាចំនួន ៥-១០ នាក់ អាស្រ័យលើភូមិសាស្ត្រ និងប្រជាសាស្ត្រនៃឃុំនីមួយៗ និងត្រូវមានស្មៀនម្នាក់ដើម្បីជួយដល់កិច្ចការរដ្ឋបាល [4, p. 8]។ នៅក្នុងខេត្តតាកែវ មានឃុំចំនួន ១០០ ដឹកនាំដោយ ក្រុមប្រឹក្សា ឃ.ស. មានចំនួន ៧៣៦ នាក់ ដែលមានក្រុមប្រឹក្សាជាស្ត្រីចំនួន ១១៧ នាក់ ។ មេភូមិជាស្ត្រីមាន ៨៦នាក់ក្នុងចំណោម ១១៩៨ នាក់ [3] ។ ក្រុមប្រឹក្សា ឃ.ស. បំពេញមុខងារធំៗចំនួន ៧ [4, 10, 11]៖ (១) សេវាកម្មរដ្ឋបាល និងការអភិវឌ្ឍន៍ប្រកបដោយ

*ក្រាហ្វិក ៤៖ រចនាសម្ពន្ធ័ក្រុមប្រឹក្សាឃុំ សង្កាត់*




*ប្រភព៖ ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០១[4]*

ប្រសិទ្ធភាព (២) ធានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ(៣) លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកប ដោយចីរភាព(៤) ការការពារធនធាន វប្បធម៌បេតិកភណ្ឌជាតិ និងបរិស្ថាន(៥) ជួយសម្រួលដល់បញ្ហា និងវិវាទរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន(៦)បំពេញការងារទូទៅដើម្បីបំពេញនូវតម្រូវការប្រជាពលរដ្ឋ និង (៧) អនុវត្ត និងអនុម័តផែនការអភិវឌ្ឍឃុំរបស់ខ្លួន។ ទាក់ទងនឹងតួនាទីរបស់ខ្លួនក្នុងនាមជាតំណាងរដ្ឋ ក្រុមប្រឹក្សាត្រូវអនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីប្រកាស និងឧបករណ៍ច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធ។

បន្ថែមលើតួនាទី និងភារកិច្ចធំៗ ដែលបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ បំពេញការងាររដ្ឋបាលរួមមាន ៖ (១)ការចុះបញ្ជីអត្រានុកូលដ្ឋាន ដូចជាសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ជាដើម និង (២) ធ្វើលិខិតបញ្ជាក់នៅលើវ មេម៉ាយ លិខិតយល់ព្រមដើម្បីរៀបចំកម្មវិធីសង្គមនិងបុណ្យទាននានា [12]។ សម្រាប់ជាការសំអាងនៃការងារឃុំកន្លងមកបានបញ្ជាក់ដោយទិន្នន័យដែលទទួលបានពីសេវាកម្មសាធារណៈទូទៅនៅការិយាល័យអត្រានុកូលដ្ឋានប៉ុណ្ណោះ ហើយការងារទាំងនោះបានទទួលស្គាល់ដោយប្រជាពលរដ្ឋ [13]។

លើសពីនេះទៀត យោងតាមប្រកាសអន្តរក្រសួងស្តីពីផ្ទេរសេវារដ្ឋបាល និងការយកកម្រៃសេវារដ្ឋបាលពីរដ្ឋាភិបាលកណ្តាលទៅឲ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិរួមទាំងរដ្ឋបាលឃុំ សង្កាត់ ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយក្នុងឆ្នាំ ២០១៦ [12]។ ការផ្ទេរនេះអនុញ្ញាតឲ្យរដ្ឋបាលឃុំ សង្កាត់បង្កើតប្រភពចំណូលផ្ទាល់ខ្លួនតាមរយៈការយកថ្លៃសេវារដ្ឋបាល។

## ៣.១. គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់(គ.ក.ន.ក)

ក្រុមប្រឹក្សាឃ.ស. មានគណៈកម្មការក្រោមចំណុះចំនួន ៤ រួមមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់(គ.ក.ន.ក.)(សូមមើលរូបភាព ៤) ។ បន្ទាប់ពីគ.ក.ន.ក. សាកល្បងការងារពីរបីឆ្នាំក្នុងឃុំចំនួន ៤២២ នៅខេត្តចំនួន ៦ ដោយក្រសួងមហាផ្ទៃ (MoI) និងកម្មវិធីយូនីសេហ្វ កម្មវិធីសិទ្ធិកុមារ ដើម្បីលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ ព្រមទាំងសិទ្ធិរបស់ស្ត្រី និងកុមារក្នុងឆ្នាំ ២០០៤ [14, p.2] គ.ក.ន.ក. ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋបាលឃុំទាំងប្រទេស ចាប់ពីឆ្នាំ ២០០៧ ដោយសេចក្តីណែនាំលេខ ០៨២ របស់ គ.ជ.អ.ប. ស្តីពីការរៀបចំ និងការបង្កើត គ.ក.ន.ក. [13, p.23]។

គ.ក.ន.ក. មានអាណត្តិដូចគ្នានឹងក្រុមប្រឹក្សា ឃ.ស. ដែរ។ សមាសភាពនៃ គ.ក.ន.ក. មានប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកដទៃទៀត។ ប្រធាន គ.ក.ន.ក. ជាមេឃុំ/ចៅសង្កាត់ ដែលមានជំទប់ទី២ ជាអនុប្រធាន និងតំណាងស្ត្រី និងកុមារ ជាសមាជិកអចិន្ត្រៃយ៍។ សមាជិកផ្សេងទៀតរួមមាន ស្មៀនឃ.ស. មេ ឬមេរងប៉ូលីសឃ.ស. នាយកសាលា ឬអ្នកតំណាង ប្រធានមណ្ឌលសុខភាព ឬអ្នក

តំណាង និងប្រធានភូមិទាំងអស់ [14, p.2] ។ សមាជិកនៃគណៈកម្មាធិការនេះអាចប្រែប្រួលអាស្រ័យលើចំនួនភូមិក្នុងឃុំ។ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី គណៈកម្មាធិការគួរតែមានសមាជិកស្ត្រីយ៉ាងតិច ៤០ ភាគរយ។

គ.ក.ន.ក. ដើរតួជាស្ថាប័នប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាឃុំលើបញ្ហាស្ត្រី និងកុមារ ដើម្បីលើកកម្ពស់សុខភាពមាតា និងកុមារ អនាម័យ សាលាមត្តេយ្យសហគមន៍ សមភាពយេនឌ័រ និងការការពារកុមារ។ គ.ក.ន.ក. ដើរតួនាទីយ៉ាងសំខាន់ក្នុងការតស៊ូមតិ ការលើកកម្ពស់ និងពង្រឹងសេវាសុខភាព និងសង្គមដល់ស្ត្រី នៅថ្នាក់មូលដ្ឋាន ព្រមទាំងក្នុងការទំនាក់ទំនងជាមួយថ្នាក់ស្រុក និងខេត្ត។ ដើម្បីធានាថា ស្ត្រី និងកុមារទទួលបានសេវាកម្មសមរម្យ និងអត្ថប្រយោជន៍ពីសេវានានា ដែលមានបរិយាប័ន្ន ព្រមទាំងគុណភាពនៅក្នុងវិស័យសង្គម និងសេដ្ឋកិច្ច។ គ.ក.ន.ក បំពេញនាទីជូនយោបល់ដល់ក្រុមប្រឹក្សាឃុំក្នុងការផ្តល់អនុសាសន៍ តស៊ូមតិ និង ជាអ្នកសម្របសម្រួល ក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់តាមដាន និងអនុវត្តសកម្មភាពនានា [15, p.9]។ គ.ក.ន.ក.ក៏មានតួនាទីដោះស្រាយបញ្ហាយេនឌ័រ ហើយគួរតែមានឥទ្ធិពលលើការងារក្រុមប្រឹក្សាក្រុង ប៉ុន្តែពួកគេត្រូវមានព័ត៌មានគ្រប់គ្រាន់ពីដំណើរការថវិកា [15, p.9]។

ជាក់ស្តែង របាយការណ៍ អង្គការទស្សនៈពិភពលោក (World Vision) នាឆ្នាំ ២០១៦ បានកត់សម្គាល់ថាកិច្ចខិតខំប្រឹងប្រែងរបស់ គ.ក.ន.ក. មិនត្រឹមតែជាតួនាទីតស៊ូមតិប៉ុណ្ណោះទេ ប៉ុន្តែបាន *ចូលរួមលើកកម្ពស់នៃការផ្តល់ការគាំទ្រសុខភាពដល់ស្ត្រីមានផ្ទៃពោះ ជួយរកដំណោះស្រាយសម្រាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ គាំទ្រ / លើកទឹកចិត្តកុមារឲ្យចូលរៀន ចូលរួមបណ្តុះបណ្តាលក្រុមយុវជនលើមុខវិជ្ជាជាច្រើន និងដោះស្រាយបញ្ហាម្តាយ និងកុមារងាយរងគ្រោះ* [16, p.32]។ កិច្ចខិតខំប្រឹងប្រែងរបស់ គ.ក.ន.ក. អាចប្រព្រឹត្តទៅបានតាមរយៈកម្មវិធីអភិវឌ្ឍន៍របស់អង្គការក្រៅរដ្ឋាភិបាល ដែលមាននៅតាមឃុំរបស់ខ្លួន ដូចជាគម្រោងលើកកម្ពស់សុខភាពស្ត្រី មាតា និងកុមារ អនាម័យ សាលាមត្តេយ្យសហគមន៍ សមភាពយេនឌ័រ និងការការពារកុមារនៅមូលដ្ឋានខ្លួន [17]។

## ៤. ផែនការថវិការក្រុមប្រឹក្សាឃុំ សង្កាត់

ការលើកផែនការថវិកាដែលអាចទុកចិត្តនៅថ្នាក់ឃុំសង្កាត់ គឺជា យុទ្ធសាស្ត្រ ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃ.ស. និង ជាពិសេស គ.ក.ន.ក. ឲ្យមានធនធានគ្រប់គ្រាន់សម្រាប់ការបំពេញភារៈកិច្ចរបស់ពួកគេឲ្យមានប្រសិទ្ធភាព។ ផ្នែកនេះព្យាយាមពិនិត្យមើលបញ្ហាប្រឈមនានាដែលក្រុមប្រឹក្សាឃុំ សង្កាត់ជួបប្រទះក្នុងការធ្វើផែនការថវិកាខ្លួន និង ដំណើការនៃផែនការថវិកាឃុំ សង្កាត់នៅក្នុងប្រព័ន្ធផែនការថវិកាជាតិ។

## ៤.១. ថវិកា ឃុំ សង្កាត់

ថវិកា ឃុំ សង្កាត់ គឺស្ថិតនៅក្នុងប្រព័ន្ធអនុម័តថវិកាថ្នាក់ក្រោមជាតិ ដែលត្រូវបានបែងចែកជាបីកម្រិត គឺ៖ រដ្ឋបាលរាជធានី ខេត្ត (២៥) រដ្ឋបាលក្រុង / ស្រុក / ខណ្ឌ (២០៣) និង រដ្ឋបាលឃុំ សង្កាត់ (១៦៤៦)[18]។ ដើម្បីជួយដល់មុខងាររបស់ឃ.ស. រដ្ឋាភិបាលបានបង្កើនមូលនិធិឃុំ សង្កាត់ ១ ភាគរយបន្ថែមនៃចំណូលចរន្ត សម្រាប់ឆ្នាំ ២០២០ និង ២០២៣ [19, p. 32] ដែលនៅឆ្ងាយពីការបង្កើនថវិកាខេត្តក្នុងឆ្នាំ ២០២០ ចំនួន ៣៥ ភាគរយ ពីឆ្នាំ ២០១៩ (ក្រាហ្វិក ៥) [1, 2]។

*ក្រាហ្វិក ៥៖ ថវិកាខេត្ត និង ឃុំ សង្កាត់ (លានរៀល)*




*ប្រភព៖ ច្បាប់ហិរញ្ញវត្ថុ ២០១៩ និង ២០២០[1, 2]*

ឧទាហរណ៍នៅឆ្នាំ ២០២០ ឃ.ស. នីមួយៗ បានទទួលថវិកាចំនួន ៨០៣.៣១៧ លានរៀលសម្រាប់ប្រតិបត្តិការរដ្ឋបាល និងដើម្បីគាំទ្រផែនការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ ក្រោមប្រព័ន្ធថវិកាជាតិបច្ចុប្បន្នសម្រាប់ប្រតិបត្តិការការងារ ឃ.ស. មានគណនីផ្ទាល់ខ្លួនដាច់ដោយឡែកពីថវិកាខេត្ត។ ក្រៅពីថវិកាថ្នាក់ក្រោមជាតិ ឃ.ស. ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់សកម្មភាពអភិវឌ្ឍន៍ពីកម្មវិធីអភិវឌ្ឍន៍អង្គការក្រៅរដ្ឋាភិបាល។ ទោះយ៉ាងណាក៏ដោយ ការប្រព្រឹត្តនេះត្រូវបានគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធប្រតិបត្តិការថវិកា ឃ.ស.។ ម្យ៉ាងវិញទៀត ឃ.ស. ក៏អាចបង្កើតប្រាក់ចំណូលមួយចំនួនពីសេវាកម្មចុះបញ្ជីរបស់ខ្លួនផងដែរ ប៉ុន្តែប្រាក់ចំណូលនេះមានតិចតួច និងមិនទៀងទាត់ដោយផ្អែកលើតម្រូវការសេវាកម្ម។

លើសពីនេះទៀត បើប្រៀបធៀបលើការចំណាយថវិកាសម្រាប់មនុស្សម្នាក់នៅ រាជធានី ខេត្ត ក្នុងឆ្នាំ ២០២០នេះ ខេត្តតាកែវទទួលបាន១៧.៩១០ រៀល សម្រាប់មនុស្សម្នាក់ ឬច្រើនជាងខេត្តព្រៃវែង និង ប៉ៃលិន ដែលជាខេត្តដែលទទួលបានថវិកាទាបបំផុត (រូបភាពទី ៦) ។ ថវិកាសម្រាប់រដ្ឋបាលខេត្តតាកែវមានចំនួន ១៨.២០៦,១១ លានរៀល និងសម្រាប់ការអភិវឌ្ឍមូលដ្ឋានមានចំនួន ១០.៦៩៤,១៧ លានរៀល [20]។

ច្បាប់ថវិកាមិនមានបញ្ជាក់ពីថវិកាដោយឡែកសម្រាប់ប្រតិបត្តិការ គ.ក.ន.ក.សម្រាប់គាំទ្រសកម្មភាពបញ្ញាបយេនឌ័ររបស់ គ.ក.ន.ក. នោះឡើយ។ សកម្មភាពបញ្ជ្រាបយេនឌ័ររបស់ គ.ក.ន.ក. គួរតែឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ឃុំប្រាំឆ្នាំ (CDP) និង ផែនការវិនិយោគរំកិលរយៈពេល ៣ ឆ្នាំ (CIP) [21]។ CDP និង CIP កំណត់នូវរាល់អាទិភាពចម្បងនៃកម្មវិធីអភិវឌ្ឍន៍ឃុំ និង តម្លៃនៃសកម្មភាពនីមួយ

ៗ។ ផែនការទាំងនេះត្រូវបញ្ជូនទៅក្រុមប្រឹក្សាក្រុង និងខេត្តដើម្បីពិនិត្យនឹងអនុម័តផ្នែកបច្ចេកទេសមុនបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គួរឲ្យកត់សម្គាល់ដែរថាបើទោះបីជារដ្ឋាភិបាលប្ដេជ្ញាបង្កើនថវិកាទ្វេដងសម្រាប់ថ្នាក់ក្រោមជាតិនៅក្នុងឆ្នាំនេះក៏ដោយ ការវិភាគច្បាប់ថវិកាឆ្នាំ ២០២០ លើការចំណាយសម្រាប់មនុស្សម្នាក់ៗ បានបង្ហាញថាខេត្តតាកែវនឹងក្លាយជាខេត្តលេខរាងទី៣ បន្ទាប់ពីខេត្តព្រៃវែង និងប៉ៃលិនដែលទទួលបានមូលនិធិ ឃ.ស ទាបជាងគេ (រូបភាពទី ៦) [2]។ ថវិកានេះប្រហែលជាមិនឆ្លើយតបទៅនឹងតម្រូវការសម្រាប់ដំណើរការប្រកបដោយប្រសិទ្ធភាពនៃក្រុមប្រឹក្សាឃ.ស. និង គ.ក.ន.ក នៅតាកែវនោះឡើយ [22, p. 8]។

*ក្រាហ្វិក ៦៖ ការចំណាយថវិកាសម្រាប់មនុស្សម្នាក់តាមបណ្ដាខេត្តនៅឆ្នាំ ២០២០*




*ប្រភព៖ ច្បាប់ថវិកា ឆ្នាំ២០២០[2]*

## ៤.២. ដំណើរការការធ្វើផែនការថវិកាឃុំ សង្កាត់

ផែនការថវិកា ឃ.ស. ត្រូវបានបង្កើតឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំដោយមានជំនួយការពីគណៈកម្មាធិការរៀបចំផែនការ និងថវិការបស់ឃុំ សង្កាត់ [21]។ ក្រុមប្រឹក្សាឃ.ស. ត្រូវអនុម័តលើគម្រោងថវិកានៅក្នុងកិច្ចប្រជុំសាធារណៈ មុនថ្ងៃទី ៣១ ខែតុលា រៀងរាល់ឆ្នាំ។ គ.ក.ន.ក ត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ [15]។ ប៉ុន្តែទោះយ៉ាងណា គ.ក.ន.ក អាចរៀបចំបានតែផែនការថវិកាសម្រាប់ការអភិវឌ្ឍ និងសេវាកម្មសង្គម ដូចជាថវិកាសម្រាប់

លើកកម្ពស់សុខភាពមាតា មត្តេយ្យសហគមន៍ អនាម័យ សមភាពយេនឌ័រ និងការការពារកុមារ ព្រមទាំងថវិកាសម្រាប់ការប្រជុំគណៈកម្មាធិការ [16]។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនផែនការថវិកានោះទៅអភិបាលខេត្តមុនថ្ងៃទី ៥ ខែវិច្ឆិការៀងរាល់ឆ្នាំ។ អភិបាលខេត្តត្រូវពិនិត្យអនុលោមតាម និងបញ្ជាក់ទទួលស្គាល់លើផែនការថវិកាឲ្យបានមុនថ្ងៃទី ៣០ ខែវិច្ឆិកា។ ក្នុងករណីអភិបាលខេត្តមិនបានបញ្ជាក់ទទួលស្គាល់លើផែនការថវិកា មេឃុំ ចៅសង្កាត់ត្រូវពិនិត្យកែសម្រួលផែនការថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័ត និងដាក់ជូនអភិបាលខេត្តម្តងទៀតសម្រាប់ការបញ្ជាក់ទទួលស្គាល់។ ក្នុងករណីមិនមានការចុះសម្រុងរវាង ក្រុមប្រឹក្សាឃុំ សង្កាត់ និង អភិបាលខេត្ត ប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវបញ្ជូនករណីនេះទៅឲ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យសម្រេចចុងក្រោយ។

ថវិការបស់ គ.ក.ន.ក. គឺពឹងផ្អែកលើការបែងចែកថវិកាពីក្រុមប្រឹក្សាឃុំ ហើយបានមកពីថវិកាអភិវឌ្ឍន៍មូលដ្ឋានសម្រាប់សេវាកម្មសង្គមដែលមានពី ៣ ទៅ ៤ ភាគរយនៃកម្មវិធីវិនិយោគ [16, p.36]។ ការបែងចែកថវិកាសម្រាប់សេវាសង្គមមានកម្រិតទាបពីព្រោះសហគមន៍ដូចជាផ្តោតតែលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ដែលផ្តល់ប្រយោជន៍ដល់សហគមន៍មួយភាគធំ។ ប្រមាណមួយភាគបីនៃគម្រោងមូលនិធិឃុំ សង្កាត់សរុបត្រូវបានវិភាជន៍សម្រាប់ការអភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធតូចតាច [23]។ ទោះជាយ៉ាងណាក៏ដោយ អាណត្តិក្រុមប្រឹក្សាឃ.ស. ជាទូទៅធ្វើសកម្មភាពមួយចំនួនដូចជាសេវាសង្គម ការការពារសង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងមូលដ្ឋានដែលមិនមានថវិកាគ្រប់គ្រាន់ [22, p. 16]។

## ៤.៣. បញ្ហាប្រឈមដែលក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក បានប្រឈមក្នុងការអនុវត្តតួនាទី

មានបញ្ហាប្រឈមមួយចំនួនដែលទាក់ទងនឹងតួនាទីក្រុមប្រឹក្សាឃ.ស. និង គ.ក.ន.ក នៅក្នុងខេត្តតាកែវមានដូចជា៖

១) **ថវិកាមានកំណត់៖** ដោយថវិកាមានកម្រឹត ព្រមទាំងមិនមានការឧបត្ថម្ភបន្ថែមសម្រាប់ការងារដែលទាក់ទងនឹង គ.ក.ន.ក សមាជិកគ.ក.ន.ក ភាគច្រើនមានការលំបាកចូលរួមឲ្យបានពេញលេញ ក្នុងការងារគ.ក.ន.ក ដោយពួកគេមានភារកិច្ចស្នូលរៀងៗខ្លួន [16, p.56, 24, p. 26]។ ថវិកាមានកំណត់សម្រាប់កិច្ចការសម្របសម្រួល និង ផ្គត់ផ្គង់សម្ភារៈឧបទ្ទេស ដើម្បីការរៀបចំការប្រជុំ ឬ អនុវត្តផែនការការងារគ.ក.ន.កឲ្យបានទៀងទាត់ [16, pp. 56-57]។ ថវិកា ឃ.ស. សម្រាប់សកម្មភាពអាទិភាពផ្សេងៗមានចំនួនតិចតួច លើកលែងតែការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ [13]។

២) **សមត្ថភាពបច្ចេកទេសមានកំណត់៖** ក្រុមប្រឹក្សា ឃ.ស. នៅតែត្រូវការជំនាញបច្ចេកទេសបន្ថែមសម្រាប់ការចុះបញ្ជី និងកែសំបុត្រកំណើតសម្រាប់ពលរដ្ឋរបស់ខ្លួន យោងតាមតម្រូវការរបស់ក្រសួង

មហាផ្ទៃ។ សម្រាប់ការធ្វើផែនការអភិវឌ្ឍ និង ផែនការវិនិយោគឃុំ ឃ.ស បានទទួលការបណ្តុះបណ្តាលជំនាញមួយចំនួនពីការផ្តល់សេវា ភាពជាអ្នកដឹកនាំ ការទំនាក់ទំនង សម្របសម្រួល និងជំនាញប្រតិបត្តិការ [22, p. 26]។ ទោះយ៉ាងណាក៏ដោយ ការបង្វឹក និងការណែនាំដល់ក្រុមប្រឹក្សាឃ.ស ក្នុងការលើកផែនការថវិកាអភិវឌ្ឍន៍ឃុំ និង វិនិយោគឃុំ នៅតែត្រូវការជាចាំបាច់។ ក្រុមប្រឹក្សាឃ.សមិនទាន់មានទំនុកចិត្តក្នុងការបំពេញបែបបទថវិកាដែលតម្រូវដោយរតនាគារខេត្ត ដោយសារតែដំណើរការ និងទម្រង់ថវិកាទាំងនោះនៅមានភាពស្មុគស្មាញចំពោះពួកគាត់។ ការងាររដ្ឋបាល ការធ្វើថវិកា និងផែនការនៃ ឃ.ស. ភាគច្រើនពឹងលើស្មៀនឃុំ សង្កាត់ [31, p. 2] ។ លើសពីនេះ សមត្ថភាពបច្ចេកទេសក្នុងសម្របសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់ក្រុមប្រឹក្សាឃ.ស. នៅមានកម្រិត ។

**៣) បន្ទុកការងាររបស់សមាជិក គ.ក.ន.ក៖** សមាជិក គ.ក.ន.ក ភាគច្រើនផ្តល់អាទិភាពដល់តម្រូវការរបស់អង្គភាព និងការទទួលខុសត្រូវរបស់ពួកគេរៀងៗខ្លួន [22, p. 26]។ បញ្ហាប្រឈមដែលឃ.ស. និង គ.ក.ន.ក ជួបប្រទះប្រហែលជានៅមានច្រើនទៀត។ ទោះជាយ៉ាងណាបញ្ហាប្រឈមដែលបានលើកឡើងមកនេះ អាចជាប្រធានបទដើម្បីសម្រួលដល់ការពិភាក្សានៅក្នុងវេទិកានាពេលខាងមុខ។

## ៤.៤. ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងផែនការថវិកា

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសំខាន់ៗត្រូវបានអនុម័តដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានចំណូល/ថវិកាដើម្បីបំពេញភារៈកិច្ចរបស់ពួកគេដូចដែលមានចែងនៅក្នុងបទបញ្ញត្តិកម្ពុជា។ ក្របខ័ណ្ឌច្បាប់មានដូចខាងក្រោម៖

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១)៖ ច្បាប់នេះផ្តោតលើ ឃុំ សង្កាត់ ដែលតំណាងឲ្យថ្នាក់ទាបបំផុតនៃរដ្ឋាភិបាលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ ច្បាប់នេះកំណត់ក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលសម្រាប់ឃុំ សង្កាត់ ដោយអនុលោមតាមគោលនយោបាយវិមជ្ឈការ និងចែងអំពីធនធានដែលមានសម្រាប់រដ្ឋបាលឃុំ សង្កាត់ ដែលរួមមានចំណូល ថវិកានឹងទ្រព្យសម្បត្តិពីប្រភពផ្សេងៗដូចជារដ្ឋាភិបាលកណ្តាល ការប្រមូលពន្ធមូលដ្ឋាន ការចូលរួមវិភាគទានជាដើម [4]។
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០០៨)៖ ច្បាប់នេះជាច្បាប់សំខាន់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុជាតិ និងថ្នាក់ក្រោមជាតិនៅកម្ពុជា។ ច្បាប់នេះក៏បានចែងផងដែរអំពីវិធីគ្រប់គ្រងថវិកាសាធារណៈ ដែលរួមមានបទបញ្ញត្តិ ការអនុវត្ត និងការត្រួតពិនិត្យ ថវិកា [10]។
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១១)៖ ច្បាប់នេះមានគោលបំណងបង្កើតប្រភពហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យមានសមត្ថភាពសក្តានុពលក្នុងការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាម

គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ [25]។

- អនុក្រឹត្យលេខ ០៦ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិចុះថ្ងៃទី ៥ ខែមករាឆ្នាំ ២០១៧ បានចូលរួមចំណែកក្នុងការផ្តល់នូវយន្តការសម្របសម្រួល និងការគ្រប់គ្រងហានិភ័យសម្រាប់ការប្រគល់ និងផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ [26]។
- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា (២០១៨-២០២៥) និងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា (២០១៩-២០២៥) មានគោលដៅចង្អុលបង្ហាញវិធីសាស្ត្រ និងផែនទីបង្ហាញផ្លូវសម្រាប់ការផ្លាស់ប្តូរប្រព័ន្ធថវិកាឆ្ពោះទៅរកការអនុវត្តថវិកា [23, 27]។

## ៥. ជម្រើសគោលនយោបាយ

គំនិតខ្លះៗខាងក្រោមនេះអាចជាយោបល់ជួយពង្រឹងសមត្ថភាពក្រុមប្រឹក្សា ឃ.ស. ជំនះបញ្ហាប្រឈមដែលបានលើកឡើងខាងលើនេះ៖

*ក្រុមប្រឹក្សាឃុំ សង្កាត់*

- បណ្តុះបណ្តាល និងណែនាំអនុវត្តជំនាញបច្ចេកទេសហិរញ្ញវត្ថុ និងថវិកាកម្មវិធី ដល់មន្ត្រីរដ្ឋបាល ឃ.ស. នៅតែជាអទិភាព[18] ។
- គ្រូបង្គោលគួរតែមានជំនាញបច្ចេកទេស និងគរុកោសល្យអប់រំមនុស្សចាស់ ដើម្បីពង្រីកវិសាលភាពនៃបច្ចេកទេសបង្រៀន ឲ្យមានការអនុវត្តន៍ទ្រឹស្តីយ៉ាងហោចណាស់៥០ ភាគរយនៃវគ្គបំពាក់បំប៉ន[18]។
- មន្ទីរជំនាញ និងរតនាគារខេត្ត បន្តកិច្ចសហការកាន់តែខ្លាំងជាមួយរដ្ឋបាលខេត្តក្នុងការគាំទ្របច្ចេកទេសថវិកា ដល់ឃ.ស. ជាពិសេស មេឃុំ និងស្មៀន[18]។ ដើម្បីជួយសម្រួលដល់ឃ.ស. ប្រហែលជាចាំបាច់ត្រូវកាត់បន្ថយភាពស្មុគស្មាញនៃដំណើរការ និងសំណុំបែបបទហិរញ្ញវត្ថុ ព្រមទាំងពិនិត្យលទ្ធភាពបញ្ជាក់ពីថវិកា យេនឌ័រ សម្រាប់ការងារសង្គមរបស់ពួកគេ [16, p. 63, 28, p. 46]។

*គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីស្ត្រី និងកុមារឃុំ សង្កាត់*

- បង្កើនការបែងចែកថវិកាតាមរយៈក្រសួងមហាផ្ទៃដល់ គ.ក.ន.ក ដើម្បីផ្តោតលើសកម្មភាពការពារ ការប្រមូលទិន្នន័យ កម្រែសម្រាប់ទៅសួរសុខទុក្ខជនរងគ្រោះដល់ផ្ទះ និងការគ្រប់គ្រងករណីរំលោភបំពានលើកុមារ និងអំពើហឹង្សាក្នុងគ្រួសារនៅតែជាអទិភាពក្នុងការធានាសណ្តាប់ធ្នាប់ និងសន្តិសុខមូលដ្ឋាន [16]។

- ក្រសួងមហាផ្ទៃសហការជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បន្តកសាងសមត្ថភាពបន្ថែមដល់ គ.ក.ន.ក លើការកសាងថវិកាកម្មវិធីយេនឌ័រសម្រាប់លើកកម្ពស់ការពារស្ត្រី និងកុមារ ការកំណត់អត្តសញ្ញាណ និងការឃ្លាំមើលកុមារងាយរងគ្រោះ ព្រមទាំងធានាសុវត្ថិភាពកុមារនៅពេលដោះស្រាយនឹងករណីអំពើហឹង្សាក្នុងគ្រួសារ រឺករណីរំលោភបំពានផ្លូវភេទ [16, 29]។
- វាគួរតែមានការបញ្ជាក់ឲ្យកាន់តែច្បាស់នូវមុខងារ គ.ក.ន.ក ពីក្រសួងមហាផ្ទៃក្នុងចូលរួមត្រួតពិនិត្យ និងការចូលរួម របស់គ.ក.ន.ក [16, p. 64]។

## ៦. សេចក្តីសន្និដ្ឋាន

វិស័យកសិកម្មនៅតែជាមូលដ្ឋានចម្បងសម្រាប់ទ្រទ្រង់ជីវភាពប្រជាជនភាគច្រើននៅខេត្តតាកែវ ដែលជាខេត្តជាប់លំដាប់ទី ៣ នៃផលិតកម្មស្រូវ បន្ទាប់ពីខេត្តព្រៃវែង និងបាត់ដំបង។ ប្រជាជនជាច្រើននៅខេត្តនេះបានទទួលរងនូវឥទ្ធិពលអាក្រក់ពីបម្រែបម្រួលអាកាសធាតុ ហេតុនេះហើយ ការជំរុញនវានុវត្តន៍នានាដែលពង្រឹងភាពស៊ាំនៃកសិកម្មទៅនឹងឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុប្រហែលជាអាចជួយប្រជាកសិករទាញយកប្រយោជន៍ពេញលេញពីកលានុវត្តភាពនៃវិស័យកសិកម្មនៅខេត្តនេះ។

ការពង្រឹងសណ្តាប់ធ្នាប់ និងសន្តិសុខសង្គមមានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់ជាទូទៅម្រាប់ខេត្តនេះនៅឆ្នាំ ២០១៨ បើធៀបនឹងចំនួនករណីដែលកត់ត្រាដោយទិន្នន័យឃុំនៅឆ្នាំ ២០១០។ ស្របនឹងនិន្នាការនេះ ស្រុកចំនួន ៧ ដែលនៅតែមានកង្វល់ធំជាងគេ ។ ទោះជាយ៉ាងណាក្តី ការសេពថ្នាំញៀន និងអំពើហឹង្សាក្នុងគ្រួសារនៅតែជាបន្ទុកដែលត្រូវដោះស្រាយ សម្រាប់ក្រុមប្រឹក្សា យ.ស និង គ.ក.ន.ក ក្នុងការធានាសណ្តាប់ធ្នាប់ និងសន្តិសុខសង្គមនៅស្រុកទាំង១០ នៃខេត្តតាកែវ។

ភាពប្រសើរឡើងឬកង្វល់ទាំងនេះក៏អាចបញ្ជាក់ពីការយកចិត្តទុកដាក់ និងការកើនឡើងនៃសមត្ថភាពអាជ្ញាធរមូលដ្ឋានដែលបានកត់ត្រានៃករណីទាំងនោះចូលក្នុងទិន្នន័យឃុំនាឆ្នាំ ២០១៨កន្លងមក។

ប្រការដែលគួកត់សម្គាល់គឺទាក់ទងនឹង លទ្ធភាពនៃក្រុម ឃុំ សង្កាត់ និងគ.ក.ន.ក ទទួលបានថវិកានៅមានកម្រឹតសម្រាប់បំពេញការងារអភិវឌ្ឍភូមិឃុំ និង លើកកម្ពស់ការយល់ដឹងពីវិបាកនៃការសេពគ្រឿងញាណ គ្រប់គ្រងកណីបទល្មើស និង វិវាទផ្សេងៗ។ ការពង្រឹងសត្តភាពធ្វើផែនកាថវិកា និងថវិកាឃុំសង្កាត់ដែលទទួលបានពីប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ នៅមានកម្រឹត មិនទាន់ឆ្លើយតបទៅនឹងអទិភាពនៃផែនការអភិវឌ្ឍនិងវិនិយោគឃុំសង្កាត់ ។ យោងទិន្នន័យដែលទទួលបានសម្រាប់ការសិក្សានេះ ថវិកាឃុំសង្កាត់មិនបានបញ្ជាក់ច្បាស់លាស់ពីថវិកាសម្រាប់ គ.ក.ន.ក នៅឡើយទេ។

ជាងនេះទៅទៀតការបំពេញសំណុំបែបបទដកនិងទូទាត់ថវិកា តម្រូវដោយរតនាគារខេត្តនៅមានភាពស្មុគស្មាញច្រើនចំពោះក្រុមប្រឹក្សា ឃ.ស។ អាស្រ័យហេតុនេះ ការបណ្តុះបណ្តាល ពង្រឹងជំនាញ ជាពិសេសទាក់ទងនឹងការធ្វើផែនការអភិវឌ្ឍ និងផែនការថវិកាសម្រាប់ ក្រុមប្រឹក្សាឃ.ស នៅតែជាអទិភាព ។ ជាការចាំបាច់ផងដែរបើមានការពិនិត្យឡើងវិញ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ពីមុខងារនៃសំរាប់ គ.ក.ន.ក ក្នុងការចូលរួមត្រួតពិនិត្យ និង មានខ្ទង់ថវិកាយេនឌ័រនៅឃុំសង្កាត់ ដែលផ្តោតលើសកម្ម- ភាពបង្ការ ការប្រមូលទិន្នន័យ ចំណាយសម្រាប់ការសួរសុខទុក្ខជនរងគ្រោះ និងឆ្លើយតបទៅនឹងករណីរំលោភបំពានលើកុមារ និងក្នុងគ្រួសារ។

# ឯកសារយោង


1. រាជរដ្ឋាភិបាលកម្ពុជា. (២០១៨). ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា, Available at: https://moicms.interior.gov.kh/view/file/1548906739.pdf [Accessed 22 Jan. 2020].

2. រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា, Available at: https://moicms.interior.gov.kh/view/file/1577668533.pdf [Accessed 22 Jan. 2020].

3. Ministry of Planning. (2018). *Commune Database* [Online]. Phnom Penh, Cambodia: NCDD. Available at: https://drive.google.com/file/d/1NTqF6pfvU7qH2WoTBcpvrORrJXAFzKpD/view [Accessed 19 Nov. 2019].

4. Royal Government of Cambodia. (2001 ). *Law on Administrative Management of the Commune/Sangkat* Cambodia, Available at: http://www.skpcambodia.com/Laws%20&%20Regulations%20of%20the%20Kingdom%20of%20Cambodia/Property%20&%20Land%20Law/LAW-01-Commune%20Administration-E.pdf [Accessed 10 Oct. 2019].

5. Virak, K.,Fabian, S.,Hanspeter, M., et al. (2014). Prevalence and risk factors of Strongyloides stercoralis in Takeo Province, Cambodia. *Parasites & Vectors,* [online] 7(1). Available at: http://www.parasitesandvectors.com/content/7/1/221 [Accessed 19 Nov. 2019].

6. Ministry of Planning. (2010). *Commune database. NCDD. Phnom Penh, Cambodia*

7. Royal Government of Cambodia, (2019). *General Population Census of the Kingdom of Cambodia 2019: Provincial Population Totals*. Phnom Penh, Cambodia: National Institute of Statistic, Ministry of Planning

8. National Committee for Sub-National Democratic Development (NCDD). (2018). *Cambodia Gazetteer Database Online* [Online]. Phnom Penh, Cambodia: NCDD. Available at: http://db.ncdd.gov.kh/gazetteer/view/index.castle [Accessed 20 Nov. 2019].

9. រដ្ឋបាលខេត្តតាកែវ. (n.a). ស្ថានភាពទូទៅ [Online]. តាកែវ, ព្រះរាជាណាចក្រកម្ពុជា: រដ្ឋបាលខេត្តតាកែវ. Available at: https://tinyurl.com/t79coq3 [Accessed 22 Jan. 2020].

10. Royal Government of Cambodia. (2008). *Law on the administrative management of Capital, Provinces, Municipalities, Districts and Khans* [Art. 36] Phnom Penh, Cambodia, Available at: http://www.cdc-crdb.gov.kh/cdc/twg_network/country_systems_cambodia/strengthening_national_systems/documents_for_reform/sndd/organic_law_2008_en.pdf [Accessed 10 Oct. 2019].

11. គណៈកម្មការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប). (២០១៩). តួនាទី និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ [Online]. ភ្នំពេញ: គ.ជ.ប. Available at: https://www.nec.gov.kh/khmer/content/2171 [Accessed 27 Jan. 2020].

12. Royal Government of Cambodia, (2016). *Inter-Ministrial Praka on the Provision of Administrative Services to Sub-National Administration*. Phnom Penh, Cambodia: Ministry of Interio, Available at: https://data.opendevelopmentmekong.net/en/dataset/inter-ministerial-prakas-no-14342-the-provision-of-administrative-services-at-sub-national-level/resource/07d62f75-db1b-4d99-b69c-02ccd1a452de [Accessed 21 Jan 2020].

13. COMFREL. (2013). *Assessment of the Second Term of Decentralization of Cambodia Commune Council Performance and Citizens' Participation,2007-2012.* Phnom Penh, Cambodia COMFREL, Available at: http://ticambodia.org/library/wp-content/files_mf/1437964917FinalreportoftheSecondTermofDDEnglish1.pdf [Accessed 13 Jan 2020 ].

14. Royal Government of Cambodia, (2008 ). *The Functioning of Commune Comittee for Women and Children (CCWC)* Phnom Penh NCDD Available at: https://kdevevelop.files.wordpress.com/2009/08/2008-hip-pocket-on-the-functioning-of-the-commune-snagkat-committee-for-women-and-childreneng.pdf [Accessed 13 Jan 2020 ].

15. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, (២០១០). សេចក្តីណែនាំស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ពន្ធ័នឹងសុខភាពមាតា មតេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំសង្កាត់. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, Available at: https://www.skpcambodia.com/storage/uploads/files/Local%20Authorities/Guideline%20051%20SNN-NCDD%20on%20CCWC%20Functioning%20for%20Social%20Development-Kh.pdf [Accessed 20 Jan. 2020 ].

16. Jordanwood, M. (2016 ). *Protecting Cambodia's Children?Phnom Penh: World Vision Cambodia.* Phnom Penh, Cambodia: World Vision Cambodia, Available at: https://www.wvi.org/sites/default/files/CCWC-Functionality-for-CP-Full-Report-EN.pdf [Accessed 13 Jan 2020 ].

17. Royal Government of Cambodia. (2019). *Cambodia Report On the occasion of the 25th Anniversary of the Fourth World Conference on Women and the adoption of the Beijing Declaration and Platform for Action (1995)* Phnom Penh, Cambodia: Royal Government of Cambodia.

18. Mom, V. and Xu, X. (2016). Commune/Sangkat Fund and Local Development: Case of Cambodia *Journal of Economics and Sustainable Development,* [online] 7(22). Available at: https://iiste.org/Journals/index.php/JEDS/article/view/34185 [Accessed 10 Jan. 2020 ].

19. រាជរដ្ឋាភិបាលកម្ពុជា, (២០២០). សេចក្តីថ្លែងហេតុ អំពី សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០. ភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា.

20. រាជរដ្ឋាភិបាលកម្ពុជា, (២០១៩). មូលនិធិឃុំសង្កាត់ឆ្នាំ២០១៨. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: រាជរដ្ឋាភិបាលកម្ពុជា.

21. Sandap, V. (2020). Commune/Sangkat financial management system and Commune/Sangkat budget planning. In*: Strengthening Capacity of the Commune/Sangkat Council for Enhancing Public Services Delivery*, Mondulkiri: Ministry of Economic and Finance, [Accessed 15 Jan. 2020].

22. Wold Bank, (2019 ). *Cambodia Nutrition Project : International Development Association Project Appraisal Document* Phnom Penh, Cambodia World Bank Available at: http://documents.worldbank.org/curated/en/598441554688835540/pdf/Cambodia-Nutrition-Project.pdf [Accessed 20 Jan 2020 ].

23. Royal Government of Cambodia. (2018). *Budget System Reform Strategy (2019-2025).* Phnom Penh, Cambodia.

24. Ministry of Interior. (2019). *The National Committee for Sub-National Democratic Development (NCDD) holds the 17th meeting* [Online]. Phnom Penh, Cambodia: Ministry of Interior. Available at: https://moicms.interior.gov.kh/view/file/1577668533.pdf [Accessed 22 Jan. 2020].

25. Royal Government of Cambodia. (2011). *Law on Financial Regime and Property Management of Sub-National Administrations (SNAs).* Phnom Penh, Cambodia.

26. Royal Government of Cambodia. (2017). *Sub-Decree 06 on the transfer of financial resources based on conditions, to sub-national administration* Phnom Penh, Cambodia.

27. Royal Government of Cambodia. (2017). *Budget System Reform Strategy (2018-2025)* Phnom Penh, Cambodia.

28. Murage, A. M. (2019 ). *Multiple Facets of Parenting in Cambodia: A Case of Siem Reap.* Phnom Penh, Cambodia: Heinrich Böll Foundation Cambodia, Available at: https://kh.boell.org/sites/default/files/hbs_final_draft_the-multiple-facets-of-parenting-in-cambodia_einzelseiten.pdf [Accessed 22 Jan 2020 ].

29. UNICEF. (2011). *Report on the internal assessment of social mapping tool.* Phnom Penh, Cambodia: UNICEF.